ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តត្បូងឃ្មុំ

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៦០
ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០២៣
សាលក្រមរដ្ឋប្បវេណីលេខ ៤០ "ក"
ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣

**សាលក្រម**
**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តត្បូងឃ្មុំ**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃចន្ទ ១១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

-និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ។

+**ដើមចោទ៖** ធនាគារកាណា[redacted]) អាសយដ្ឋានអគារលេខ [redacted] ដោយមានលោក[redacted] វង្សា ជាអ្នកតំណាង។

+**អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី [redacted]អគ្គលេខ ១៨០៩ លោកស្រីមេធាវី [redacted]អគ្គលេខ ១៥៥២ កញ្ញាមេធាវី [redacted]អគ្គលេខ ២១៦៦ កញ្ញាមេធាវី [redacted]អគ្គលេខ ២២៤៦ និងលោកមេធាវី [redacted]អគ្គលេខ ២៧០៦T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាសយ[redacted]។

+**សហចុងចម្លើយ៖**

១-ឈ្មោះ [redacted]ាន់ជឿន ភេទប្រុស កើតឆ្នាំ១៩៦៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២៥០០៦៦១៥១ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥។

២-ឈ្មោះ [redacted]ិដោ ([redacted] ពិដោរ) ភេទស្រី កើតឆ្នាំ១៩៧៥ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២៥០០០៧១០០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។

៣-ឈ្មោះ [redacted] លាងហេង ភេទប្រុស កើតឆ្នាំ១៩៥៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២៥០០៦៦០០០ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥។

៤-ឈ្មោះ [redacted] នាង ភេទស្រី កើតឆ្នាំ១៩៥៣ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២៥០០០៧១០២ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤។

[redacted]។

+**អ្នកតំណាងដោយអាណត្តិ៖** គ្មាន។



Scanned with CamScanner

**ក-ខ្លឹមសារសាលក្រម៖**

**ក.១-ខ្លឹមសារសាលក្រមដែលទាមទារដោយដើមចោទ៖**

ដើមចោទស្នើសុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យសហចុងចម្លើយសងប្រាក់មកដើមចោទនូវប្រាក់ជំពាក់ដូចខាងក្រោម៖

I.បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៧២៤** (B<sub></sub>II ០៣២៥/០០០៦) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិក្រែកត្បូង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៥២៧** (BII ០៣១៣) ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៧២៩** (BII ០៣២៨/០០០៦) ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៦៥៥** (BII ០៣២១/០០០៣) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិទួលអង្គ្រង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

II.បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដែលនៅជំពាក់ទាំងអស់មកឱ្យដើមចោទរួមមាន៖

១.ប្រាក់ដើមសរុបចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)**។

២.ការប្រាក់គិតចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ **៨% (ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំ លើប្រាក់សរុបចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)**។

៣.សំណងនៃការខូចខាត (ការប្រាក់ពិន័យ) គិតចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ក្នុងអត្រា **១៦% (ដប់ប្រាំមួយភាគរយ)** ក្នុងមួយឆ្នាំ លើប្រាក់ដើមសរុបចំនួន **KHR** ១.៨២៦.៤៨៣.១៨៥(មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិប**ប្រាំរៀលគត់**)។

៤.សេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន **KHR ១៦០.០០០.០០០ (មួយរយហុកសិបលានរៀលគត់)**។

៥.ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។

៦.សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នបានត្រង់ចំណុចទីII (១, ២ និង៣)ខាងលើ។

**ក.២-ខ្លឹមសារសាលក្រមដែលទាមទារដោយសហចុងចម្លើយ៖**

-សហចុងចម្លើយឈ្មោះ[redacted]ពិរោះ ([redacted] ពិរោះ)៖



Scanned with CamScanner

១-ទទួលស្គាល់ការទាមទាររបស់ដើមចោទ ត្រង់ចំណុចទីI និងចំណុចទីII (**ទី១ និងទី២**)

២-ច្រានចោលការទាមទាររបស់ដើមចោទ ត្រង់ចំណុចផ្សេងទៀតក្រៅពីនេះ។

## ខ-<u>អង្គហេតុ និងចំណុចវិវាទ៖</u>

### ខ.១-សេចក្តីសង្ខេប៖

កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ឈ្មោះ[redacted] **វ៉ាន់ធឿន**, ឈ្មោះ [redacted] **ពិដោ** ([redacted] **ពិដោរ**), ឈ្មោះ [redacted] **លាងហេង** និងឈ្មោះ[redacted] **នាង** បានចុះកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម) ពី **ធនាគារ**[redacted] ដែលមានទឹកប្រាក់សរុបចំនួន **KHR ១.៨៦៧.២៩០.៦៤៨(មួយពាន់ប្រាំបីរយហុកសិបប្រាំពីរលានពីររយកៅសិបពាន់ប្រាំមួយរយសែសិបប្រាំបីរៀលគត់)** ក្នុងអត្រាការប្រាក់ ៨% (**ប្រាំបីភាគរយ**) ក្នុងមួយឆ្នាំ រយៈពេលខ្ចីប្រាក់**៦០ខែ** ដោយធ្វើការសងរំលស់ប្រាក់ដើម និងការប្រាក់ថេរចំនួន **KHR ២០.០០០.០០០ (ម្ភៃលានរៀលគត់)** ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៥ និងនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ សងផ្តាច់ប្រាក់ដើម និងការប្រាក់ដែលនៅសល់ជាក់ស្តែង។ របៀបនៃការសងប្រាក់ត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ **ធនាគារ** ដោយការសងប្រាក់ដើម និងការប្រាក់មួយលើកៗ ត្រូវកាត់យកជាស្វ័យប្រវត្តិពីគណនីរបស់សហចុងចម្លើយដូចមានចែងក្នុងប្រការ**១.២.១** នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម)លេខ **០៦៧៩/២០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន សហចុងចម្លើយមិនបានគោរពកាតព្វកិច្ចនៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានបង់ប្រាក់ដើម និងការប្រាក់ ជូនធនាគារអស់ជាច្រើនខែ ទោះបីជា **ធនាគារ** បានធ្វើការក្រើនរំលឹកជាច្រើនលើកច្រើនសារក៏ដោយ ក៏សហចុងចម្លើយនៅតែមិនព្រមអនុវត្តកាតព្វកិច្ចនោះដែរ។

យោងតាមតារាងបញ្ជាក់ពីស្ថានភាពបំណុលរបស់ **ធនាគា**[redacted] បំណុលរបស់ឈ្មោះ [redacted] **វ៉ាន់ធឿន**, ឈ្មោះ [redacted] **ពិដោ** ([redacted] **ពិដោរ**), ឈ្មោះ [redacted] **លាងហេង** និងឈ្មោះ [redacted] **នាង** នៅជំពាក់ប្រាក់ដើមសរុបចំនួន **KHR** ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់) រួមទាំងការប្រាក់ និងការប្រាក់ពិន័យ(សំណងការខូចខាត) គិតចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១។

### ខ.២-អង្គហេតុដែលគ្មានវិវាទ៖

-សហចុងចម្លើយទទួលស្គាល់ការទាមទារ ត្រង់ចំណុចទីI និងចំណុចទីII (**ទី១** ប្រាក់ដើម និង**ទី២**ការប្រាក់) ដូចការលើកឡើងរបស់ដើមចោទពិតប្រាកដមែន គ្រាន់តែចុងចម្លើយមិនមានលទ្ធភាពសងនាពេលនេះ។

### ខ.៣-ចំណុចវិវាទ៖

១/.តើដើមចោទអាចប្តឹងទាមទារប្រាក់កម្ចីពីចុងចម្លើយបានដែរ ឬទេ? ឬត្រូវទុកពេលវេលាឱ្យចុងចម្លើយរកប្រាក់សងដើមចោទវិញ?

២/.តើមានអត្ថិភាពនៃអង្គហេតុស្តីពីការប្រាក់ពិន័យ ដែរ ឬទេ?

៣/.តើដើមចោទទទួលរងនូវការខូចខាតផ្នែកជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ ដែរ ឬទេ?

៤/.តើមានភាពចាំបាច់ដែលត្រូវប្រកាសឱ្យអនុវត្តសាលក្រមជាបណ្តោះអាសន្ន ដែរ ឬទេ?។

### ខ.៤-ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ៖

#### ខ.៤.១-ការអះអាងរបស់ភាគីដើមចោទ៖

លោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានថ្លែងការណ៍ថានៅក្នុងរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការសម្រេចចេញសាលក្រម ដែលមានខ្លឹមសារដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ និងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣ ទុកជាបានការដដែល ដោយមិនមានការកែប្រែឡើយ។



Scanned with CamScanner

ឆ្លើយតបទៅនឹងចំណុចវិវាទទី១, ទី២, ទី៣ និងទី៤ ខ្លួនជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ សូមថ្លែងការណ៍ដូចតទៅ៖

-ចំណុចវិវាទទី១ មូលហេតុដែលធនាគារប្តឹងទាមទារឱ្យសហចុងចម្លើយសងប្រាក់ជំពាក់នាពេលនេះ គឺដោយសារតែសហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងការបង់ប្រាក់ជូនដើមចោទ តាមកាលកំណត់ដូចមានក្នុងតារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២។

-ចំណុចវិវាទទី២ ផ្អែកតាមប្រការ ៣ អំពីការបំពានកិច្ចសន្យា ត្រង់ចំណុច ៣.១ បានចែងថា ករណីភាគី "ក" ខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងឥណទានតាមកាលកំណត់ដូចក្នុងតារាងបង់ប្រាក់នោះ ភាគី "ក"យល់ព្រមបង់ប្រាក់សំណងនៃការខូចខាតតាមចំណុច ១.៤ ក្នុងប្រការ១ នៃកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម) យើងខាងលើដោយគិតចាប់ពីថ្ងៃទី៤ នៃចំនួនថ្ងៃដែលបានខកខានសងរហូតដល់បំណុលត្រូវបានសងបញ្ចប់ទាំងស្រុង។ ដូច្នេះ អាចបញ្ជាក់បានថា ដើមចោទពិតជាមានអត្ថិភាពក្នុងការទាមទារប្រាក់ពិន័យពីចុងចម្លើយប្រាកដមែន។

-ចំណុចវិវាទទី៣ ធនាគារត្រូវចំណាយសោហ៊ុយផ្សេងៗលើនីតិវិធី និងមានកាតព្វកិច្ចបង់ការប្រាក់ទៅឱ្យអ្នកដាក់បញ្ញើ ម្យ៉ាងទៀតវាបានធ្វើឱ្យខូចផែនការអាជីវកម្ម ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយ។

-ចំណុចវិវាទទី៤ ដើម្បីកុំឱ្យពន្យារពេលនីតិវិធី ជាហេតុធ្វើឱ្យការប្រាក់មានកើនឡើងធ្វើឱ្យខូចប្រយោជន៍ដល់ភាគីទាំងសងខាង និងមានភាពចាំបាច់សម្រាប់ដើមចោទជាធនាគារ ដែលចាំបាច់ត្រូវតែមានលំហូរសាច់ប្រាក់ល្អប្រសើរ និងមិនអាចទុកឱ្យមានបំណុលខូច ឬបំណុលដែលមិនអាចទារបានក្នុងរយៈពេលយូរនោះទេ។ ម្យ៉ាងវិញទៀតសហចុងចម្លើយបានទទួលស្គាល់ចំពោះការទាមទាររបស់ដើមចោទលើប្រាក់ដើម និងការប្រាក់ ផងដែរ គឺជាសក្ខីកម្មមួយដែលបញ្ជាក់ច្បាស់លាស់អំពីអត្ថិភាព នៃសិទ្ធិការទាមទាររបស់ដើមចោទលើចំនួនទឹកប្រាក់ដើម និងការប្រាក់ដែលនឹងពុំមានការប្រែប្រួលឡើយ។

ខ.៤.២-<u>ការអះអាងរបស់ភាគីសហចុងចម្លើយ</u>

**-សហចុងចម្លើយឈ្មោះ [redacted] ពិរោះ ([redacted]ពិរោះ) បានធ្វើសេចក្តីថ្លែងការណ៍ថា ដូចតទៅ៖** ចំពោះការប្តឹងទាមទាររបស់ធនាគារដែលស្នើសុំឱ្យខ្លួន និងគ្រួសារ រួមគ្នាសងប្រាក់ជំពាក់សរុបចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)** និងការប្រាក់ **៨% (ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំនោះ ខ្លួនទទួលស្គាល់ការទាមទារនេះ។ ប៉ុន្តែសុំឱ្យធនាគារអនុគ្រោះចំពោះការទាមទារឱ្យខ្លួនសងនៅពេលនេះ ព្រោះខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ ដោយសារការរកស៊ីមិនអាចរកប្រាក់ចំណូលដូចមុន ដោយកូនបំណុលដែលជំពាក់ប្រាក់ខ្លួនមិនមានលទ្ធភាពសងលុយខ្លួន បញ្ហានេះកើតឡើងចំពេលកូវីដផងដែរ។

ដោយឡែកចំពោះការទាមទាររបស់ដើមចោទ ត្រង់ចំណុចផ្សេងទៀត ខ្លួនសុំច្រានចោលការទាមទារនេះ ព្រោះខ្លួនមិនមានលទ្ធភាពសងប្រាក់ទៅដើមចោទទេ ហើយការទាមទារត្រង់ចំណុចទាំងនេះមានចំនួនច្រើនលើសលប់ពេក ក្នុងករណីដែលតុលាការសម្រេចឱ្យខ្លួនទទួលរ៉ាប់រងត្រង់ចំណុចនេះទៀត វារឹតតែជាបន្ទុកធ្ងន់ធ្ងរបន្ថែមទៀតសម្រាប់ខ្លួន។

ដោយឡែកពាក់ព័ន្ធការទាមទារឱ្យប្រកាសសាលក្រមអាចអនុវត្តជាបណ្តោះអាសន្ន គឺខ្លួនសុំឱ្យតុលាការសម្រេចច្រានចោល ដោយហេតុថាខ្លួនស្នើសុំលក់ទ្រព្យធានានេះដោយខ្លួនឯងបានតម្លៃជាងលក់តាមផ្លូវតុលាការ។



Scanned with CamScanner

## ការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយ

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយថា ខ្លួនសំណូមពរសុំឱ្យតុលាការចេញសាលក្រមសម្រេចតាមការទាមទាររបស់ធនាគារដែលមានខ្លឹមសារដូចក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ ទុកជាបានការដដែល។

-សហចុងចម្លើយឈ្មោះ **ហេង ពិដោ** បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយថា ការទាមទាររបស់ដើមចោទជាច្រើនចំណុចខាងលើមានលក្ខណៈធ្ងន់ធ្ងរ ដូច្នេះស្នើសុំឱ្យតុលាការសម្រេចតាមច្បាប់។

**គ-អំពីភស្តុតាង៖**

១.តារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

២.តារាងលែស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ចំនួន ០១ ច្បាប់។

៣.កិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម)លេខ **០៦៧៩/០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

៤.ឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម) លេខ **០៦៧៩/២០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

៥.តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

៦.កិច្ចសន្យាបង្កើតហ៊ីប៉ូតែក(រួមបន្ថែម) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ចំនួន ០១ ច្បាប់។

៧.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៧២៤(B₁₁ ០៣២៥/០០០៦)** ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ចំនួន ០១ ច្បាប់។

៨.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៥២៧ (B₁₁ ០៣១៣)** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ចំនួន ០១ ច្បាប់។

៩.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៧២៩ (B₁₁ ០៣២៨/០០០៦)** ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ ចំនួន ០១ ច្បាប់។

១០.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៦៥៥ (B₁₁ ០៣២១/០០០៣)** ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ ចំនួន ០១ ច្បាប់។

១១.លិខិតជូនដំណឹងសងប្រាក់(លើកទី១) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។

១២.លិខិតជូនដំណឹងសងប្រាក់(លើកទី២) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។

១៣.លិខិតជូនដំណឹងសងប្រាក់ (លើកទី៣) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ ចំនួន ០១ ច្បាប់។

១៤.អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ [redacted] វ៉ាន់ធឿន, ឈ្មោះ [redacted] **ពិដោ** ([redacted] **ពិដោរ**), ឈ្មោះ [redacted] លាងហេង និងឈ្មោះ [redacted] នាង។

**សំអាងហេតុ៖**

**ក-ការវិនិច្ឆ័យអំពីចំណុចវិវាទទី១ និងការទាមទារប្រាក់ដើម និងការប្រាក់៖**

១-តាមការអះអាងរបស់ភាគីដើមចោទ និងសហចុងចម្លើយ និងការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ រួមមាន៖ តារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០, តារាងលែស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២, កិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម)លេខ **០៦៧៩/០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០, ឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម) លេខ **០៦៧៩/២០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០, តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០, កិច្ចសន្យាបង្កើតហ៊ីប៉ូតែក(រួមបន្ថែម) ចុះថ្ងៃទី



Scanned with CamScanner

២២ ខែតុលា ឆ្នាំ២០២០, លិខិតជូនដំណឹងសងប្រាក់(លើកទី១) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២១, លិខិតជូនដំណឹងសងប្រាក់(លើកទី២) ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ និងលិខិតជូនដំណឹងសងប្រាក់ (លើកទី៣) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២១ បញ្ជាក់ឱ្យឃើញថា សហចុងចម្លើយពិតជាបានបង្កើតកិច្ចសន្យាខ្ចីចងការប្រាក់ ព្រមទាំងបានទទួលប្រាក់កម្ចីពីដើមចោទប្រាកដមែន។

២-ភាគីសហចុងចម្លើយបានថ្លែងការណ៍ថា ចំពោះការប្ដឹងទាមទាររបស់ធនាគារដែលស្នើសុំឱ្យខ្លួន និងគ្រួសាររួមគ្នាសងប្រាក់ជំពាក់សរុបចំនួន **KHR១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)** និងការប្រាក់ ៨% **(ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំ នោះ ខ្លួនទទួលស្គាល់ការទាមទារនេះ។ ប៉ុន្តែសុំឱ្យធនាគារអនុគ្រោះចំពោះការទាមទារឱ្យខ្លួនសងនៅពេលនេះ ព្រោះខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ នោះ គឺបញ្ជាក់បានថាសហចុងចម្លើយបានទទួលស្គាល់នូវអត្ថិភាព និងចំនួននៃទឹកប្រាក់ជំពាក់ដូចការអះអាងរបស់ដើមចោទពិតមែន។ ហេតុដូច្នេះគប្បីតុលាការទទួលស្គាល់នូវអង្គហេតុជំពាក់ និងអត្ថិភាព ព្រមទាំងចំនួននៃទឹកប្រាក់ ដោយពុំចាំបាច់ពិនិត្យលើភស្តុតាង ស្របតាមកថាខណ្ឌទី **២** មាត្រា **១២៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣-ការដែលសហចុងចម្លើយមិនព្រមសងប្រាក់ខាងលើនៅពេលនេះ ដោយមូលហេតុថា ខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ ដោយសារការរកស៊ីមិនអាចរកប្រាក់ចំណូលដូចមុន ដោយកូនបំណុលដែលជំពាក់ប្រាក់ខ្លួនមិនមានលទ្ធភាពសងលុយខ្លួន បញ្ហានេះកើតឡើងចំពេលកូវីដផងដែរនោះ គឺជាការអះអាងមិនត្រឹមត្រូវទេ ព្រោះថាភាគីសហចុងចម្លើយបានបំពានលើករណីយកិច្ចរបស់ខ្លួនជាកូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច ដែលតាមបញ្ញត្តិមាត្រា **៣៨៤** (ករណីយកិច្ចរបស់កូនបំណុលក្នុងការអនុវត្តកាតព្វកិច្ច) នៃក្រមរដ្ឋប្បវេណី ចែងថា "កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់" ហើយតាមរយៈនេះម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការបាន តាមបញ្ញត្តិមាត្រា ៣៨៥ (សិទ្ធិរបស់ម្ចាស់បំណុលក្នុងការទាមទារឱ្យអនុវត្តកាតព្វកិច្ច) នៃក្រមរដ្ឋប្បវេណី។

៤-ជាមួយគ្នានេះដែរ តុលាការយល់ឃើញថា ការទាមទារប្រាក់ដើម និងការប្រាក់ គឺជាការទាមទារត្រឹមត្រូវផងដែរ ដោយហេតុថា កិច្ចសន្យានេះត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងដើមចោទ និងសហចុងចម្លើយ និងធ្វើឡើងដោយភ្ជាប់ការប្រាក់ ដោយបានកំណត់អត្រាការប្រាក់ជាលាយល័ក្ខណ៍អក្សរច្បាស់លាស់ និងត្រឹមត្រូវតាមច្បាប់ ស្របតាមបញ្ញត្តិមាត្រា **៥៧៩** (ការបង្កើតកិច្ចសន្យាខ្ចីបរិភោគ) និងមាត្រា **៥៨៣** (សិទ្ធិលើបំណុលដែលជាការប្រាក់) នៃក្រមរដ្ឋប្បវេណី និងស្របតាមប្រការ ៤ នៃប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទានលេខ **ធ៧-០១៧-១០៩ ប្រ.ក** ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា (ដែលមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញ ដែលចុះកាលបរិច្ឆេទចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧) ដែលកំណត់ឱ្យគ្រឹះស្ថានហិរញ្ញវត្ថុ និងធនាគារមានសិទ្ធិក្នុងការកំណត់អត្រាការមិនឱ្យលើសពី **១៨%** (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ។

-តាមរយៈសំអាងហេតុខាងលើ បានបង្ហាញឱ្យឃើញថា ភាគីសហចុងចម្លើយពិតជាមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាកូនបំណុលក្នុងការទូទាត់សងប្រាក់ទៅឱ្យដើមចោទតាមកាលកំណត់ ដូចមានចែងក្នុងកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម)លេខ **០៦៧៩/០២០ ឥ.ទ** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ប្រាកដមែន។ ហេតុដូច្នេះ តុលាការទទួលស្គាល់នូវការប្តឹងទាមទារឱ្យសងប្រាក់របស់ដើមចោទនៅពេលនេះ និងសម្រេចឱ្យសហចុងចម្លើយសងប្រាក់ដើម និងការប្រាក់តាមការទាមទាររបស់ដើមចោទ ទុកជាការទាមទារត្រឹមត្រូវ។

៥-ចំពោះថិរវេលានៃការគិតការប្រាក់ដែលដើមចោទទាមទារ ក្នុងអត្រាការប្រាក់ ៨% **(ប្រាំបីភាគរយ)** ក្នុងមួយឆ្នាំ គិតលើប្រាក់ដើមចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)** គិតចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃសងគ្រប់ចំនួន តុលាការយល់ឃើញថាជាការ



Scanned with CamScanner

ណាសហចុងចម្លើយមិនទាន់សងប្រាក់រួចរាល់ ការគណនាការប្រាក់ត្រូវធ្វើជាបន្តតាមសមាមាត្រនៃអត្រាការប្រាក់គុណនឹងប្រាក់ដើមដែលនៅជំពាក់រហូតដល់ថ្ងៃសងគ្រប់។

**ខ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី២ ការទាមទារប្រាក់ពិន័យៈ**

១-ភាគីសហចុងចម្លើយបានបដិសេធ ចំពោះការទាមទាសំណងនៃការខូចខាត (កាប្រាក់ពិន័យ) ក្នុងអត្រា**១៦%** (ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ គិតលើប្រាក់ដើមសរុប **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)** ដោយហេតុថា ខ្លួនមិនមានលទ្ធភាពសងតាមការទាមទាររបស់ដើមចោទទេ ដោយសារការរកស៊ីមិនអាចរកប្រាក់ចំណូលដូចមុន ដោយកូនបំណុលដែលជំពាក់ប្រាក់ខ្លួនមិនមានលទ្ធភាពសងលុយខ្លួនបញ្ហានេះកើតឡើងចំពេលកូវីដផងដែរ។ ត្រង់ចំណុចនេះតុលាការពិនិត្យឃើញថា ការលើកឡើងរបស់សហចុងចម្លើយនេះពុំមានមូលហេតុត្រឹមត្រូវឡើយ ដោយហេតុថា ក្រៅពីការទាមទារការប្រាក់ ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន ស្របតាមបញ្ញត្តិមាត្រា ៣៩៨ ដល់មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណី។

២-ជាមួយគ្នានេះ គូភាគីក៏បានកំណត់ជាមុននូវចំនួននៃសំណងការខូចខាត ដូចមានចែងក្នុងប្រការ *៣ អំពីការបំពានកិច្ចសន្យា ត្រង់ចំណុច ៣.១ បានចែងថា ករណីភាគី "ក" ខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងឥណទានតាមកាលកំណត់ដូចក្នុងតារាងបង់ប្រាក់នោះ ភាគី "ក" យល់ព្រមបង់ប្រាក់សំណងនៃការខូចខាតតាមចំណុច ១.៤ ក្នុងប្រការ១ នៃកិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម) យើងខាងលើដោយគិតចាប់ពីថ្ងៃទី៤ នៃចំនួនថ្ងៃដែលបានខកខានសងរហូតដល់បំណុលត្រូវបានសងបញ្ចប់ទាំងស្រុង"* គឺជាខចែងពិសេសដែលគូភាគីបានព្រមព្រៀងអំពីការកំណត់ជាមុននូវចំនួននៃសំណងក្នុងករណីមិនអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលមានកម្មវត្ថុជាប្រាក់ស្របតាមបញ្ញត្តិមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី ដែលតុលាការមិនអាចបន្ថែម ឬបន្ថយចំនួននេះបានទេ (លើកលែងតែចំនួននេះច្រើនហួសហេតុពេក ឬតិចហួសហេតុពេក)។ តាមរយៈនេះ ដោយហេតុថា ពុំទាន់មានបញ្ញត្តិស្តីពីការកម្រិតកំណត់លើអត្រានៃសំណងនេះសម្រាប់វិស័យធនាគារ និងហិរញ្ញវត្ថុនេះនៅឡើយ ហើយបើយោងតាមប្រកាសលេខ **១២៨ កយ.ប្រក/១១** ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត បានកំណត់អំពីអត្រាសំណងនេះមិនលើសពី **២៧% (ម្ភៃប្រាំពីរភាគរយ)** ដូច្នេះតុលាការត្រូវសម្រេចអំពីការទាមទារប្រាក់ពិន័យ ស្របតាមការតាមការទាមទារនេះ។

៣-យោងតាមតារាងបញ្ជាក់ពីស្ថានភាពបំណុល ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ដែលចេញដោយធនាគារ [redacted] បានបញ្ជាក់ថា សហកូនបំណុលឈ្មោះ [redacted]វ៉ាន់ធឿន, ឈ្មោះ [redacted] ពិដោ, ឈ្មោះ [redacted] លាងហេង និងឈ្មោះ [redacted]នាង ពិតជាបានខកខានសងប្រាក់ទៅដើមចោទ ចាប់តាំងពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ មកប្រាកដមែន ហើយបើពិនិត្យតាមប្រការ ៣ (៣.១) នៃឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម) លេខ ០៦៧៩/០២០ ត.១ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ ដែលបានចែងថា *"ករណីភាគី "ក" ខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងឥណទានតាមកាលកំណត់ដូចក្នុងតារាងបង់ប្រាក់នោះ ភាគី"ក" យល់ព្រមបង់ប្រាក់សំណងនៃការខូចខាតតាមចំណុច ១.៤ ក្នុងប្រការ ១ នៃកិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម) យើងខាងលើដោយគិតចាប់ពីថ្ងៃទី៤ នៃចំនួនថ្ងៃដែលបានខកខានសងរហូតដល់បំណុលត្រូវបានសងបញ្ចប់ទាំងស្រុង"*។ ដូច្នេះនាំឱ្យការកំណត់បរិច្ឆេទនៃការគិតប្រាក់ពិន័យ ចាប់គិតពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ តទៅ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

**គ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី៣ ការទាមទារសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជំងឺចិត្តៈ**

ឆ្លើយតបទៅនឹងការទាមទារ ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងសំណងជំងឺចិត្ត មានចំនួនសរុប KHR ១៦០.០០០.០០០ (មួយរយហុកសិបលានរៀលគត់) ដែលភាគីចុងចម្លើយបានបដិសេធចំពោះការទាមទាររបស់ភាគីដើម



Scanned with CamScanner

ចោទទាំងស្រុងនោះ តុលាការយល់ឃើញថា ការដែលសហចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចសងប្រាក់កម្ចីទៅឱ្យដើមចោទបែបនេះ គឺពិតជាធ្វើឱ្យដើមចោទមានការខាតបង់ថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលា ដោយសារតែសហចុងចម្លើយជាអ្នកមានកំហុសដែលមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ទោះបីជាដើមចោទបានជូនដំណឹងទៅសហចុងចម្លើយដើម្បីឱ្យអនុវត្តកាតព្វកិច្ចជាច្រើនសារ ក៏ដោយក៏សហចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចដដែល ហើយការបំពានកាតព្វកិច្ចនេះ បានធ្វើប៉ះពាល់ដល់លំហូរសាច់ប្រាក់របស់ដើមចោទមានការកក់ស្ទះផងដែរ។ ដូច្នេះគប្បីតុលាការសម្រេចឱ្យសហចុងចម្លើយ សងសំណងការខូចខាតទៅឱ្យដើមចោទ ដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ច ទំហំនៃការខូចខាត និងជីវភាពរបស់សហចុងចម្លើយ ស្របតាមមាត្រា ៤០០ និងមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី។

**ឃ-ការវិនិច្ឆ័យអំពីចំណុចវិវាទទី៤ ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន៖**

ពាក់ព័ន្ធនឹងការស្នើសុំរបស់ភាគីដើមចោទ ដែលបានស្នើសុំឱ្យតុលាការប្រកាសថាសាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាននោះ តុលាការយល់ឃើញថា សាលក្រមនេះជាសាលក្រមដែលសម្រេចអំពីការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ និងមានភាពចាំបាច់សម្រាប់ដើមចោទជាធនាគារដែលចាំបាច់ត្រូវតែធានាឱ្យមានលំហូរសាច់ប្រាក់ល្អប្រសើរ និងមិនអាចទុកឱ្យមានបំណុលខូច ឬបំណុលដែលមិនអាចទារបានក្នុងរយៈពេលយូរនោះទេ។ ម្យ៉ាងវិញទៀតការទាមទារនេះទៀតសោត ក៏មានមូលហេតុ និងភស្តុតាងបញ្ជាក់ការទាមទារត្រឹមត្រូវ និងច្បាស់លាស់ ដូច្នេះអាចឱ្យតុលាការធ្វើការប្រកាសថាសាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានលើប្រាក់ដើម និងការប្រាក់ ដោយពុំចាំបាច់ឱ្យដាក់ប្រាតិភោគ ស្របតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ង-ការវិនិច្ឆ័យអំពីការទាមទារ៖**

ដើមចោទបានប្តឹងទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ត.យ ០០០៧២៤ (B<sub>II</sub> ០៣២៥/០០០៦) ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិក្រែកត្បូង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៥២៧ (B<sub>II</sub> ០៣១៣)** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.យ ០០០៧២៩ (B<sub>II</sub> ០៣២៨/០០០៦)** ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ត.យ ០០០៦៥៥ (B<sub>II</sub> ០៣២១/០០០៣) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិទួលអង្រ្កង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

តាមរយៈនេះតុលាការយល់ឃើញថា តាមការពិនិត្យលើកិច្ចសន្យាខ្ចីបរិភោគ(រួមបន្ថែម)លេខ **០៦៧៩/០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០, ឧបសម្ព័ន្ធកិច្ចសន្យាខ្ចីបរិភោគ (រួមបន្ថែម) លេខ **០៦៧៩/២០២០ ត.១** ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក(រួមបន្ថែម) ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បានបញ្ជាក់ថា សហចុងចម្លើយពិតជាបានបង្កើតហ៊ីប៉ូតែកលើអចលនវត្ថុខាងលើជាមួយដើមចោទប្រាកដមែន ស្របតាមមាត្រា ៨៤៣ និងមាត្រា



Scanned with CamScanner

៨៤៤ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះគប្បីតុលាការទទួលស្គាល់ការទាមទាររបស់ដើមចោទត្រង់ចំណុចនេះ ស្របតាមមាត្រា ៨៤៦ នៃក្រមរដ្ឋប្បវេណី។

**ច-ការវិនិច្ឆ័យអំពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី៖**

ដោយហេតុថាការប្ដឹងទាមទារនេះកើតចេញពីកំហុសរបស់សហចុងចម្លើយដែលបានបំពានក្នុងការអនុវត្តកាតព្វកិច្ច នោះ គប្បីសម្រេចអំពីប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ស្របតាមមាត្រា **៦៤** នៃក្រមនីតិវិធីរដ្ឋប្បវេណីស្របតាមការទាមទាររបស់ដើមចោទ។

## សេចក្ដីសម្រេចបញ្ចប់៖

I.ដើមចោទ **ធនាគារ**[redacted] មានអត្ថិភាពនៃសិទ្ធិហ៊ីប៉ូតែកលើអចលនវត្ថុដូចខាងក្រោម៖

១.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៧២៤ (B<sub></sub>II ០៣២៥/០០០៦)** ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិក្រែកត្បូង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

២.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៥២៧ (B II ០៣១៣)** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៣.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៧២៩ (B II ០៣២៨/០០០៦)** ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ មានទីតាំងស្ថិតនៅភូមិពើក ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

៤.ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ត.ឃ ០០០៦៥៥ (B II ០៣២១/០០០៣)** ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិទួលអង្រ្កង ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី(រួមទាំងសំណង់ទាំងអស់នៅលើដីនេះ)។

II.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ **[redacted] វ៉ាន់ធឿន** ឈ្មោះ **[redacted] ពិដោ (ហេង ពិដោរ)** ឈ្មោះ **[redacted] លាងហេង** និងឈ្មោះ **[redacted] នាង** រួមគ្នាសងដោយកាតព្វកិច្ចសាមគ្គីទៅឱ្យដើមចោទ [redacted] (ដោយមានលោក [redacted] ជាអ្នកតំណាង និងលោកមេធាវី [redacted] កញ្ញាមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ) នូវប្រាក់ជំពាក់ដូចខាងក្រោម៖

១-ប្រាក់ដើមសរុបចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)**។

២-ការប្រាក់ **៨%** (ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ គិតលើប្រាក់ដើមចំនួន **KHR ១.៨២៦.៤៨៣.១៨៥** (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់) គិតចាប់ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

៣-សំណងនៃការខូចខាត (ការប្រាក់ពិន័យ) ក្នុងអត្រា **១៦% (ដប់ប្រាំមួយភាគរយ)** ក្នុងមួយឆ្នាំ គិតលើប្រាក់ដើមចំនួន **KHR ១.៨២៦.៤៨៣.១៨៥ (មួយពាន់ប្រាំបីរយម្ភៃប្រាំមួយលានបួនរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំរៀលគត់)** គិតចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់។

៤-ថ្លៃសេវាកម្មច្បាប់ និងការខាតបង់ពេលវេលាចំនួន **KHR ៤០.០០០.០០០ (សែសិបលានរៀលគត់)**។ ការទាមទារលើសពីនេះសម្រេចច្រានចោល។



Scanned with CamScanner

៥-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុចII (ទី១ ប្រាក់ដើម និងទី២ ការប្រាក់) នៃសេចក្ដីសម្រេចបញ្ចប់។

៦-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះត្រូវបានប្រកាសជាសាធារណៈនៅសវនាការទី៣ នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។ ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល០១(មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្បូងឃ្មុំ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ត្បូងឃ្មុំ, ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner